# ការជជែកមួយ
# ទីអានគុម អំពីព្រះគម្ពីរ

*ទីអានគុម មកពីប្រទេស ហ្វីជី ។ យើងបាន សួរគាត់នូវសំណួរមួយចំនួនអំពីរបៀបដែល គាត់បានរៀនចេញពីព្រះគម្ពីរមរមន ។*



### សូមប្រាប់យើងអំពីខ្លួនរបស់ប្អូន

ខ្ញុំមានអាយុប្រាំបួនឆ្នាំ ហើយជាកូនពៅក្នុងចំណោមកូនប្រាំមួយនាក់ ។ ពណ៌ដែលខ្ញុំចូលចិត្តគឺពណ៌ក្រហម ហើយអាហារដែលខ្ញុំចូលចិត្តគឺការីសាច់មាន់ជាមួយបាយ ។ ខ្ញុំចូលចិត្តលេងបាល់ឱប ! អ្វីដែលពិសេសអំពីខ្ញុំគឺឈ្មោះរបស់ខ្ញុំ ។ គោត្តនាមរបស់ខ្ញុំគឺមកពីអ្នកចម្បាំងនៃព្រះគម្ពីរមរមន ឈ្មោះកណ្ដាលរបស់ខ្ញុំគឺមកពីឪពុករបស់ខ្ញុំនៅប្រទេស នីហ្សេរីយ៉ា ហើយត្រកូលរបស់ខ្ញុំគឺហ្វីជី ។







### តើព្រះគម្ពីរបានជួយប្អូនៗដោយរបៀបណា ?

ព្រះគម្ពីររំឭកខ្ញុំឲ្យមានភាពក្លាហាន និងហ៊ានអធិស្ឋានទូលសូមការលួងលោមចិត្ត ។ ពេលណាដែលខ្ញុំភ័យខ្លាច ឬឯកោ ខ្ញុំដឹងថាព្រះវិញ្ញាណបរិសុទ្ធនឹងលួងលោមខ្ញុំជានិច្ច ។



### តើដំណើររឿងនៃព្រះគម្ពីរមរមនដែលអ្នកចូលចិត្តជាងគេនោះគឺជារឿងអ្វី ?

រឿងដែលខ្ញុំចូលចិត្តពីព្រះគម្ពីរមរមនគឺដំណើររឿងអំពី ទីអានគុម ពីព្រោះគាត់ជាអ្នកដឹកនាំ និងជាអ្នកចម្បាំងដ៏អស្ចារ្យ ។ គាត់បានប្រយុទ្ធដើម្បីគ្រួសារ មិត្តភក្តិ និងសាសនាចក្ររបស់គាត់ ។ ខ្ញុំដឹងថាខ្ញុំក៏អាចដូចគាត់ដែរ ហើយតែងតែការពារអ្វីដែលខ្ញុំស្រឡាញ់បំផុត ។

### តើអ្វីដែលបានជួយប្អូនរៀនចេញពីព្រះគម្ពីរ ?

ខ្ញុំចូលចិត្តអានព្រះគម្ពីរជាមួយគ្រួសារខ្ញុំ ។ យើងសិក្សាមេរៀនចេញមកពី *ចូរមកតាមខ្ញុំ* ជាមួយគ្នា ។ ខ្ញុំចូលចិត្តរៀនដំណើររឿងថ្មីៗជារៀងរាល់សប្ដាហ៍ ។ យើងនិយាយអំពីអ្វីដែលយើងរៀន ហើយចែកចាយទីបន្ទាល់របស់យើងជាមួយគ្នាទៅវិញទៅមក ។ ពេលខ្ញុំអានព្រះគម្ពីរ ខ្ញុំក៏ចូលចិត្តស្រមៃថាខ្លួនខ្ញុំនៅក្នុងដំណើររឿងនានាផងដែរ ។



### តើប្អូននឹងផ្ដល់ដំបូន្មានអ្វីខ្លះដល់នរណាម្នាក់ដែលមានការលំបាកក្នុងការយល់ដឹងពីព្រះគម្ពីរ ?

ប្រសិនបើនរណាម្នាក់កំពុងស្មុគស្មាញក្នុងការរៀនពីព្រះគម្ពីរ នោះពួកគេអាចសុំម្ដាយ ឬឪពុករបស់ពួកគេ ឬសូម្បីតែបងប្អូនបង្កើតរបស់ពួកគេឲ្យជួយពួកគេបាន ។ គ្រួសាររបស់ខ្ញុំពិតជាបានជួយខ្ញុំ ។ ប្អូនក៏អាចសួរគ្រូបង្រៀនអង្គការបឋមសិក្សា ឬអ្នកដឹកនាំនៅសាសនាចក្រផងដែរ !